## សំណួរ

## តើអ្វីទៅ វិធានអន្តរជាតិដែលមានតម្លៃខាងគេបំផុត (*Jus Cogens*)?

## ចម្លើយ

វាមានភាពច្បាស់លាស់ណាស់សម្រាប់ច្បាប់ជាតិ បើគេនិយាយអំពីឋានានុក្រមនៃច្បាប់ សម្រាប់ដោះស្រាយនូវពេលមានទំនាស់រវាងច្បាប់។ ច្បាប់រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូល ហើយដែលច្បាប់ទាំងអស់ត្រូវតែស្របនឹងច្បាប់នេះ (មាត្រា ១៥០ ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣)។ ក្នុងពេលមុន អ្នកស្រាវជ្រាវមានមន្ទិលអំពី ឋានានុក្រមនៃវិធានច្បាប់អន្តរជាតិ។ តែក្រោយពីមាន អនុសញ្ញា ស្តីពី ច្បាប់សន្ធិសញ្ញាឆ្នាំ ១៩៦៩ គេចាប់ផ្តើមទទួលស្គាល់នូវវិធាន ដែលមានតម្លៃខ្ពស់ជាងគេ។ តើវិធាននោះជាអ្វីទៅ?

មាត្រា ៥៣ ជាវិធានអន្តរជាតិទូទៅ ដែលមានតម្លៃខ្ពស់ ឈ្នះវិធានទាំងឡាយដែលមានទំនាស់ជាមួយ និងមានតែវិធានដែលមានតម្លៃស្រដៀងគ្នា ទើបអាចជំនួសបាន។[1] អ្នកស្រាវជ្រាវ មានទស្សនៈខ្វែងគ្នាអំពីវិធានអ្វីដែលស្ថិតក្នុងប្រភេទនៃវិធាននេះ។ ការបំពានវិធាននេះ មានផលប៉ះពាល់ធ្ងន់ធ្ងរ នាំឲ្យរដ្ឋណាមួយក៏អាចអន្តរាគមន៍ទប់ស្កាត់ឬឆ្លើយតប នឹងការបំពាន។ ក្នុងករណីខ្លះ រដ្ឋអាចឆ្លើយតបដោយបំពាន ដើម្បីផលប្រយោជន៍ខ្លួន ឬក្រុមរបស់ខ្លួន ប្រឆាំងនឹងរដ្ឋ ឬក្រុមរដ្ឋបដិបក្ខ ក្រោមលេសថា រដ្ឋខាងក្រោយបានបំពានវិធានប្រភេទនេះ។ អាស្រ័យហេតុនេះ មានការឯកភាពគ្នាថា មានវិធានប្រភេទនេះតិចតួច ដែលទទួលបានការឯកភាព មានដូចជា ការហាមឃាត់អំពើប្រល័យពូជសាសន៍ (prohibition of genocide) ការហាមឃាត់អំពើទាសភាព (slavery) និងអំពើទារុណកម្ម (prohibition of torture) ជាដើម។

---

[1] សន្ធិសញ្ញា ត្រូវចាត់ទុកជាមោឃៈ ក្នុងករណីដែលវាផ្ទុយទៅនឹងបទដ្ឋានខ្ពស់បំផុតនៃច្បាប់អន្តរជាតិទូទៅ នៅពេលចុះសន្ធិសញ្ញានោះ។ សម្រាប់គោលបំណងនៃអនុសញ្ញានេះ បទដ្ឋានខ្ពស់បំផុតនៃច្បាប់អន្តរជាតិទូទៅ គឺជាបទដ្ឋានដែលត្រូវបានទទួលយក និងទទួលស្គាល់ដោយសហគមអន្តរជាតិនៃរដ្ឋទាំងមូល ថាជាបទដ្ឋានដែលមិនអនុញ្ញាតឱ្យមានបទដ្ឋានផ្សេងទៀត មានឧត្តមភាពលើសវាបានឡើយ ហើយវាអាចត្រូវបានធ្វើវិសោធនកម្ម តែដោយបទដ្ឋានបន្ទាប់ទៀតនៃច្បាប់អន្តរជាតិទូទៅ ដែលមានចរិកលក្ខណៈដូចគ្នាប៉ុណ្ណោះ, *see* United Nations, *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 18 September 2019] (VCLT)

ក្នុងពេលកំពុងអនុវត្តកាតព្វកិច្ច រដ្ឋត្រូវផ្អាក បើមានវិធានប្រភេទនេះកើតឡើង ផ្ទុយនឹងកាតព្វកិច្ចនេះ។ សន្ធិសញ្ញាដែលខ្ទាស់ត្រូវទុកជាមោឃៈ និងត្រូវបញ្ចប់ (មាត្រា ៦៤ នៃ VCLT) នឹងរួចផុតពីការទទួលខុសត្រូវទៀតផង( Drafted Articles on State Responsibility)។[2]

អ្វីដែលគួរឲ្យកត់សំគាល់ គឺថា ទោះបីវិធានណាមួយចូលក្នុងប្រភេទនេះក្តី ក៏មិនអាចឈ្នះ ឬអនុវត្តបានដោយស្វ័យប្រវត្តិទេ។ ក្នុងន័យនេះ អ្នកស្រាវជ្រាវមិនអាចចេះតែអះអាងថា ត្រូវតែគោរព អនុវត្តតាម វិធាននេះ ដោយមិនពិចារណា អំពីតម្រូវការនៃវិធាននៃនីតិវិធីសម្រាប់អនុវត្ត វិធាននេះ ដែលជាច្បាប់សារជាតុទេ។ ឧទាហរណ៍ គេមិនអាចបកស្រាយឲ្យរដ្ឋណាមួយ សងសំណងដល់ជនរងគ្រោះ នៃអំពើទារុណកម្ម ដែលកើតនៅទីណាក៏ដោយ ដោយគ្មានពាក់ព័ន្ធនឹងរដ្ឋនេះ ដោយសារតែ ការហាមឃាត់ទារុណកម្មជា វិធានមានតម្លៃខ្ពស់ជាងគេនោះទេ។

**Further Readings**: Kamrul Hossain, *The Concept of Jus Cogens and the Obligation Under The U.N. Charter*, 3 Santa Clara J. Int'l L. 72 (2005). Available at: http://digitalcommons.law.scu.edu/scujil/vol3/iss1/3; Cherif Bassiouni, *International Crimes Jus Cogens and Obligatio Erga Omnes* (online version); Thomas Kleinlein, *Jus Cogens Re-Examined: Value Formalism in International Law*, 28(1) The European Journal of International Law, 2017.

---

[2] Article 26. Compliance with peremptory norms Nothing in this chapter precludes the wrongfulness of any act of a State which is not in conformity with an obligation arising under a peremptory norm of general international law, International Law Commission, *Draft Articles on Responsibility of States for Internationally Wrongful Acts*, November 2001, Supplement No. 10 (A/56/10), chp.IV.E.1, available at: https://www.refworld .org/docid/3ddb8f804.html [accessed 18 September 2019].